ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេស ដាំដំណាំឪឡឹក









រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ឆ្នាំ២០១៧



រក្សាសិទ្ធិគ្រប់យ៉ាង ដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# សៀវភៅ

## ស្ដីពី

## បច្ចេកទេសដាំដំណាំឪឡឹក

## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
## នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីបច្ចេកទេសដាំដំណាំឪឡឹក

I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ហ៊ាន វណ្ណាហាន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន វុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៤. លោក **គីម ដា៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

III. អ្នកស្រាវជ្រាវ:

១. លោកស្រី **កែវ ចាន់ដារី** ក្រុមហ៊ុន EAST-WEST SEED INTERNATIONAl Ltd.,

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **កេត សំអាត** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

២. លោក **ផន ប្រុស** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៣. លោក **ហុង ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៤. លោក **ឈុន សុភ័ក្រ** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# មាតិកា ទំព័រ


I. ស្ថានភាពទូទៅ........................................................................០១

II. បច្ចេកទេសដាំដុះ.......................................................................០១

១. ការជ្រើសរើសពូជ...........................................................................០១

២. ការជ្រើសរើស និងរៀបចំដី..............................................................០២

៣. ការធ្វើរោងបណ្តុះកូនឪឡឹក..............................................................០៨

៤. ការបណ្តុះគ្រាប់...............................................................................១០

៥. ការដាំកូនឪឡឹកមានពីររបៀបគឺការដាំដោយគ្រាប់ផ្ទាល់ និងការដាំដោយបណ្តុះកូន..............................................................................................១៣

៦. ការថែទាំ........................................................................................១៥

៦.១. ការប្រើប្រាស់ជី.........................................................................១៥

៦.២. ការស្រោចទឹក...........................................................................១៨

៦.៣. ការជម្រះស្មៅ...........................................................................១៩

៦.៤. ការតាក់តែងមែក.......................................................................១៩

៧.ជំងឺ និងសត្វល្អិតចង្រៃ......................................................................២០

៧.១. ជំងឺដំណាំឪឡឹក.........................................................................២០

៧.២. សត្វល្អិតចង្រៃ...........................................................................២៥

៨. ការប្រមូលផល................................................................................២៧




# ដំណាំឪឡឹក
# Watermelon

## I. ស្ថានភាពទូទៅ

មានដំណាំយកផ្លែជាច្រើនប្រភេទ ដែលស្ថិតនៅក្នុងក្រុមបន្លែផង និងជាដំណាំឈើហូបផ្លែផង ដូចជាដំណាំឪឡឹកជាដើម ដោយផ្លែរបស់វាត្រូវបានគេបរិភោគខ្ចីៗក្នុងតំបន់ប្រទេសក្រីក្រមួយចំនួន ដែលមិនសំបូរបន្លែ ប៉ុន្តែដោយឡែកចំពោះប្រទេសភាគច្រើន គេតែងតែបរិភោគផ្លែទុំជាបង្អែម ហើយមានប្រជាប្រិយ៍ភាពយ៉ាងខ្លាំងស្ទើរពាសពេញពិភពលោក។



## II. បច្ចេកទេសដាំដុះ

### ១. ការជ្រើសរើសពូជ

នៅក្នុងការដាំដុះ ពូជជាកត្តាសំខាន់ជាងគេ ពូជមានច្រើនប្រភេទដូចជាពូជស្រាល ពូជកណ្ដាល និងពូជធ្ងន់ ពូជទាំងនេះមិនអាចសមស្របសម្រាប់ការដាំដុះនៅគ្រប់តំបន់នោះឡើយ មានពូជខ្លះសមស្របនឹងអាកាសធាតុត្រជាក់

ពូជខ្លះសមស្របនឹងអាកាសធាតុក្តៅ ជាពិសេសពូជក្នុងស្រុកតាមការជ្រើសរើស និងសំរិតសំរាំងអាចទុកពូជបាន។ ចំពោះពូជ Hybrid F1 ជាពូជសុទ្ធដែលបានឆ្លងកាត់ការបង្កាត់ ពូជប្រភេទនេះមិនអាចយកគ្រាប់ទុកពូជបានទេ ព្រោះជាពូជត្រូវបានផលិតដោយក្រុមហ៊ុនជាច្រើនលើពិភពលោក។ ប៉ុន្តែក្នុងនោះ ពូជដែលផលិតដោយក្រុមហ៊ុន នៅក្នុងតំបន់អាស៊ីដូចជា ជប៉ុន តៃវ៉ាន់ ចិន ថៃ វៀតណាម ភាគច្រើនអាចដុះលូតលាស់ល្អ ក្នុងប្រទេសកម្ពុជាយើង។



## ២. ការជ្រើសរើស និងរៀបចំដី

### ❁ ការជ្រើសរើសដី៖

ដើម្បីឱ្យការដាំដុះទទួលបានជោគជ័យ គេត្រូវជ្រើសរើសដីដោយផ្អែកលើលក្ខខណ្ឌដូចតទៅ៖

ប្រភេទដីល្បាប់ ដីល្បាយខ្សាច់ ដីក្រហមជើងភ្នំ ដីខ្មៅខ្លង់រាប ដីមានជីជាតិល្អ ស្រទាប់ដាំដុះជ្រាបទឹកបានរហ័ស មាន pH ៥-៦.៨ ជាមធ្យមជាពិសេសគឺមិនត្រូវការដីដែលដាំដំណាំអំបូរត្រសក់ ននោង ល្ពៅ ម្រះ ឃ្លោកពីរដូវមុនមកដាំឪឡឹកឡើយ ហើយម្យ៉ាងទៀត វាមិនឆ្លើយតបទៅលើប្រភេទដីឥដ្ឋខ្លាំង ដែលហៅថាGlay soil។

### ❁ ការរៀបចំដី

ដំបូងត្រូវរាស់យកកាកសំណល់ផ្សេងៗ និងស្មៅចង្រៃចេញពីចម្ការឱ្យស្អាត បន្ទាប់មកភ្ជួរដីហាលឱ្យបានយូរថ្ងៃ ដើម្បីឱ្យដីស្អួតល្អ។

- ភ្ជួរដីជម្រៅ ២តឹកទៅ៣តឹក (២០សង់ទីម៉ែត្រទៅ៣០សង់ទីម៉ែត្រ)
- ចំពោះការភ្ជួរដីត្រូវធ្វើឱ្យបាន ២-៣ដងមុនពេលដាំ




## ផលប្រយោជន៍នៃភ្ជួររាស់ដី៖

- កំចាត់សត្វល្អិតចង្រៃ និងជំងឺនៅក្នុងដី
- ដីធូរ មានខ្យល់ចេញចូលបានល្អ ឬសដំណាំដុះលូតលាស់លឿន
- អាចរក្សាសំណើមដីបានល្អសម្រាប់ដំណាំ។

## ការលើករងដាំ

ដើម្បីឱ្យកូនឪឡឹកដុះលូតលាស់បានល្អបន្ទាប់ពីដាំហើយ កសិករត្រូវតែចាប់ផ្ដើមលើករងឱ្យហើយទើបចាប់ផ្ដើមបណ្ដុះគ្រាប់ឪឡឹកនៅពេលជាមួយគ្នា។ របៀបធ្វើរងដាំឪឡឹកមានដូចខាងក្រោម៖

- ទទឹងរង ១ម៉ែត្រ ទៅ ១,៥ ម៉ែត្រ
- បណ្ដោយរងធ្វើតាមលទ្ធភាពតែមិនគួរលើសពី ២៥ម៉ែត្រទេ។ ការលើករងវែងពេកយើងនឹងពិបាកចូលស្រោចទឹក ធ្វើស្មៅ ដាក់ជី បាញ់ថ្នាំនិងប្រមូលផល។
- លើករងនៅរដូវវស្សាកំពស់ពី២,៥តឹក-៣តឹក (២៥សង់ទីម៉ែត្រ-៣០សង់ទីម៉ែត្រ)
- ចន្លោះពីគុម្ពមួយទៅគុម្ពមួយទៀតមានប្រវែង ១ម៉ែត្រ
- ចន្លោះពីជួរមួយទៅជួរមួយទៀតមានប្រវែង ៣ ម៉ែត្រ




* ច្របល់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្ត១-២ គីឡូក្រាមលាយជាមួយ

ជី អិន ប៉េ កា (N.P.K) (២០.២០.១៥) ចំនួន ១០ក្រាម (១ស្លាបព្រាបាយ) សម្រាប់ឪឡឹក ១ដើម ឬ ជី ២០.២០.១៥ ចំនួន ៣,៣ គ.ក្រ សម្រាប់ ផ្ទៃដី៥០០ម² ជៀសវាងដាក់ជីលាមក



សត្វមិនទាន់ពុកផុយពីព្រោះវាបង្ក ឱ្យកូនឪឡឹករលួយ។

### ផលប្រយោជន៍នៃការដាក់ជីទ្រាប់បាត៖

* ដាក់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្តទ្រាប់បាតជួយឱ្យដីធូ ឫសងាយដុះលូតលាស់
* ដាក់ជី អិន ប៉េ កា (N.P.K)ទ្រាប់បាតគឺជំរុញកូនឪឡឹកទើបដាំរួចដុះលូតលាស់ឫសបានច្រើននិងរឹងមាំហើយ ដើម និងស្លឹកដុះបានឆាប់រហ័ស។
* ស្រោចទឹកលើរងដាំឱ្យជោគដល់ខាងក្នុងរងមុនគ្របប្លាស្ទីកឬចំបើង



### ផលប្រយោជន៍ នៃការស្រោចទឹកមុនគ្របរង៖

* ដីត្រជាក់ កូនឪឡឹកងាយដុះលូតលាស់
* កាត់បន្ថយចំនួនកូនឪឡឹកសន្លប់ (អន់)ឬងាប់ក្រោយពីដាំ។

* គ្របរងដាំ៖ បន្ទាប់ពីដាក់ជីទ្រាប់បាតនិងស្រោចទឹកតាមរងឱ្យជោគហើយកសិករអាចចាប់ផ្តើមគ្របរងបាន។ មានសម្ភារពីរប្រភេទអាចជ្រើសរើសយកមកគ្របរងដាំដំណាំឪឡឹកគឺ៖

### ក. ប្លាស្ទីកគ្របដីនិងរបៀបប្រើ

យើងដំឡើងប្លាស្ទីកគ្របដីតាមរងដាំឪឡឹកនីមួយៗតាមវិធីខាងក្រោម៖

* ទាញជុំប្លាស្ទីកតាមបណ្តោយរងដោយយកស្រទាប់ ពណ៌សដាក់ខាងលើនិងស្រទាប់ពណ៌ខ្មៅដាក់ខាងក្រោម

### អត្ថប្រយោជន៍នៃកៅស៊ូប្លាស្ទិក

- ផ្ទៃពណ៌សខាងលើនៃប្លាស្ទីកមានតួនាទីសំខាន់ សម្រាប់ស្រូបយកពន្លឺថ្ងៃ ដើម្បីធ្វើរស្មីសំយោគ និងបំលែងដល់ដំណាំឪឡឹក

- ផ្ទៃពណ៌ខ្មៅនៃប្លាស្ទីកគ្របវាមានតួនាទីសម្រាប់ការពារស្មៅមិនឱ្យដុះ ការពារសត្វល្អិត រក្សាសំណើមក្នុងរងបានយូរ ធ្វើឱ្យដំណាំឪឡឹកដុះលូតលាស់បានល្អ និងផ្តល់ទិន្នផលខ្ពស់។

- រីឯកៅស៊ូប្លាស្ទីកពណ៌សលាតក្រាស់ដែលមានលក់នៅលើទីផ្សារ មិនអាចយកមកគ្របលើរងដំណាំបានទេ ព្រោះវាបង្កឱ្យខូចទ្រង់ទ្រាយដីក្នុងរង ពុល គ្មានអ៊ុកស៊ីសែនចេញចូល និងអាចធ្វើរលួយឫសតែម្តង។




- ខ្ទាស់បន្ទះឫស្សី ពីលើប្លាស្ទីកជាប់នឹងដីនៅគល់ និងចុងរងឱ្យញឹក។




- ទាញប្លាស្ទីក តាមបណ្តោយរងរួចយកបន្ទះឫស្សីខ្ទាស់តាមគែមរងប្រវែង ៣-៤ តឹក សម្រាប់ខ្ទាស់មួយកន្លែង




- ប្រើខ្នាត វាស់វែង ចន្លោះគុម្ព
- ចុងខ្នាតចាក់ទំលុះ ប្លាស្ទិកសម្រាប់ដៅ ចោះរណ្ដៅ ដាំកូន ឪឡឹក
- ប្រវែងខ្នាតអាស្រ័យ តាមប្រភេទដំណាំ។




- ចោះរណ្ដៅតាមខ្នាត បានដៅទុក
- ប្រើកំប៉ុងក្ដៅ( ដាក់ រងើកភ្លើង )ឬឧបករណ៍ផ្សេងៗ ទៀត សម្រាប់ចោះរណ្ដៅ លើប្លាស្ទិក
- កំប៉ុងសម្រាប់ចោះ គួរមានមុខកាត់ ១ តឹកកន្លះ។

បើមុខកាត់ វាតូច កំដៅងាយឆួលពីក្រោមប្លាស្ទិកធ្វើឱ្យស្ងោកឬងាប់កូនឪឡឹកបន្ទាប់ពីដាំហើយ។

## ២. ការគ្របចំបើងនិងរបៀបប្រើ



គ្របចំបើងកម្រាស់ពី ០,៦តឹក ទៅ ១តឹក (៦សង់ទីម៉ែត្រ ទៅ ១០សង់ទីម៉ែត្រ)

### អត្ថប្រយោជន៍នៃការប្រើចំបើង៖

វាផ្តល់ផលប្រយោជន៍ច្រើននៅរដូវប្រាំងដូចជា៖

- រក្សាសំណើមដីបានយូរ
- កាត់បន្ថយការហូរច្រោះដីរងដំណាំ និងជួយដីធូរបន្ទាប់ពីចំបើងរលួយ
- ដីរងមិនហាប់ (ដីនៅធូរ) ធ្វើឱ្យឫសដំណាំងាយដុះបានលឿន
- កាត់បន្ថយការបាត់បង់ជី
- កាត់បន្ថយការដុះស្មៅ

## ៣. ការធ្វើរោងបណ្តុះកូនឪឡឹក

ការបណ្តុះកូនឪឡឹកមិនបានត្រឹមត្រូវតាមបច្ចេកទេស នោះកសិករ និងមានការខាតបង់ជាច្រើនដូចជា៖

- ខាតបង់គ្រាប់ដោយសារគ្រាប់មិនដុះ និងមានចំនួនកូនឪឡឹកងាប់ច្រើន
- កសិករត្រូវការពេលវេលាថៃទាំច្រើន និងចំណាយទិញជីច្រើនសម្រាប់បំប៉នឪឡឹកបន្ទាប់ពីដាំហើយ
- កសិករ និងមិនអាចប្រមូលផលឬប្រមូលផលបានតិចដោយសារកូន

ឪឡឹកក្រិនឬមានជំងឺ

- កូនឪឡឹកមានសុខភាពខ្សោយ ងាយរងការបំផ្លាញ ពីសត្វល្អិតចង្រៃ និងជំងឺ នៅក្រោយពេលដាំហើយ

ដើម្បីទទួលបានទិន្នផលខ្ពស់ ត្រូវដាំតែកូនឪឡឹកណាដែលមានសុខភាពល្អហើយថ្លោស។

**វិធីផលិតកូនឪឡឹកបានល្អ៖**

- ត្រូវសង់រោងនៅកន្លែងណាដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និងមិននៅក្បែរដើមឈើ

- ដំបូលត្រូវមានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់មកលើកូនឪឡឹក។ ជៀសវាងធ្វើដំបូលរានកូនឪឡឹកពីស្លឹកដូង

- តង់ពណ៌ខៀវ ឬពីសម្ភារផ្សេងទៀតដែលមិនអាចឱ្យពន្លឺចូលរួចពីព្រោះវានិងធ្វើឱ្យគ្រាប់ឪឡឹកដុះយឺត ដើមកូនឪឡឹកទន់ ឬងាយរលួយគល់កូនឪឡឹក ។

- ដំបូលរោងបណ្ដុះកូនមានកម្ពស់ពី២ ម៉ែត្រ ទៅ២ម៉ែត្រកន្លះ ដែលមានដំបូលគ្របសំណាញ់ ពណ៌ខៀវដើម្បីកាត់បន្ថយពន្លឺ និងកំដៅថ្ងៃ នៅរដូវប្រាំង និងគ្របដំបូលសំណាញ់ពណ៌សដើម្បីទាញពន្លឺថ្ងៃចូល សម្រាប់កូនឪឡឹកធ្វើរស្មីសំយោគនៅរដូវវស្សា

- រានបណ្ដុះគួរមានកម្ពស់កន្លះម៉ែត្រ (0,៥ម)ពីដី ហើយរាននេះអាចធ្វើពីឬស្សី ក្ដារ និងសម្ភារដទៃទៀតក៏បានដែរ។ តែមិនត្រូវក្រាលដី បាវក្រចៅ ឬសម្ភារដែលជក់ទឹកទ្រាប់ពីក្រោមថាសបណ្ដុះ ឬកន្ទោងបណ្ដុះទេ ពីព្រោះវាអាចនាំមកជាមួយនូវជំងឺ និងធ្វើឱ្យឫសចាក់ចុះហួសកន្ទោងបណ្ដុះ។

- គ្របសំណាញ់ពណ៌សដើម្បីការពារសត្វល្អិតបំផ្លាញ។

- កៅស៊ូប្លាស្ទីក មិនអាចគ្របកូនឪឡឹកក្នុងថ្នាលបណ្ដុះផ្ទាល់បានទេ ពីព្រោះវាធ្វើឱ្យកូនឪឡឹកអន់ ឬងាប់តែម្ដងប៉ុន្តែកៅស៊ូប្លាស្ទីកអាចគ្របធ្វើជាដំបូលរោងថ្នាលបណ្ដុះកូនឪឡឹកបាន។





(ក)រានបណ្ដុះកូនឪឡឹកសម្រាប់រដូវប្រាំង (ខ)រានបណ្ដុះកូនឪឡឹកសម្រាប់រដូវវស្សា

**ផលប្រយោជន៍នៃការធ្វើរានបណ្ដុះ៖**

- អាចការពារកូនដំណាំ ពីការឆ្លងជំងឺ និងសត្វល្អិតចង្រៃ
- បញ្ចៀសការរលួយកូនដំណាំឪឡឹកនៅរដូវវស្សា និងក្រិននៅរដូវក្ដៅ
- កាត់បន្ថយការឆ្លងជំងឺ ដែលហូរតាមដីមកលើកូនឪឡឹក

## ៤. ការបណ្ដុះគ្រាប់

### ❁ ការរៀបចំដីបណ្ដុះ

យកដីមានជីជាតិ ១ភាគលាយជាមួយជីលាមកគោស្ងួត ឬ ជីកំប៉ុស្ដ ២ភាគ និងផេះអង្កាមពី ២ ទៅ ៣ភាគ អាស្រ័យតាមប្រភេទដី (ផេះអង្កាមត្រូវត្រាំទឹករយៈពេលចាប់ពី មួយអាទិត្យឡើងទៅ ដើម្បីកាត់បន្ថយជាតិប្រៃនៅក្នុងផេះអង្កាមនោះ ពីព្រោះផេះអង្កាមសំបូរទៅដោយជាតិប្រៃច្រើន។ មិនអាចប្រើអង្កាមស្រស់លាយជាមួយដីបណ្ដុះបានទេ ព្រោះអាចធ្វើឱ្យគ្រាប់ពូជឪឡឹកឬ

គ្រាប់ពូជបន្លែផ្សេងៗមិនអាចដុះពន្លកបាន ឬក៏ដុះពន្លកហើយតែត្រូវរលួយ ឬ ងាប់ទៅវិញតែម្តង។ បន្ទាប់មកយកល្បាយដែលបានលាយច្របល់ហើយទៅលីងឬចំហុយរហូតក្តៅសព្វ មួយរយភាគរយតែត្រូវឱ្យដីនោះនៅសើមតិចៗទើប មិនខូចគុណភាពដី។




**ផលប្រយោជន៍នៃការរៀបចំដីសម្រាប់បណ្ដុះគឺ ៖**

- គ្រាប់ងាយដុះឫស ហើយដុះលូតលាស់ល្អ
- កូនឪឡឹកមានជីគ្រប់គ្រាន់សម្រាប់ចិញ្ចឹមដើម ស្លឹក ឫស
- សម្លាប់មេរោគ( ជំងឺ ) ដែលបង្កឱ្យកូនឪឡឹករលួយ
- សម្លាប់គ្រាប់ស្មៅចង្រៃដែលដុះដណ្តើមយកជីពីកូនឪឡឹក
- សម្លាប់ពងសត្វល្អិត និង សត្វល្អិតចង្រៃនៅក្នុងដីបំផ្លាញគ្រាប់ឪឡឹក

## ការបណ្ដុះគ្រាប់ឪឡឹក

- យកដីបណ្ដុះបានលីង ឬចំហុយហើយដាក់ក្នុងកន្ទោង ឬ ថាសបណ្ដុះ

តែជៀសវាងសង្កត់ដីនោះ










- ស្រោចទឹកឱ្យជោគដីល្មមទើបយក ដីនោះទៅដាក់ក្នុងថាសបណ្ដុះ




- ដាក់គ្រាប់ឪឡឹក១គ្រាប់ក្នុង១ប្រលោះ ថាសបណ្ដុះ ឬ១កន្ទោងរួចយកដី រោយលុបពីលើគ្រាប់។ មិនត្រូវ កប់ គ្រាប់ជ្រៅនោះទេ វាអាចធ្វើឱ្យគ្រាប់ រលួយ ឬដុះយឺត។

## ៥. ការដាំកូនឪឡឹកមានពីររបៀបគឺ ការដាំដោយគ្រាប់ផ្ទាល់ និងការដាំដោយកូនបណ្តុះ

ក. ការដាំដោយគ្រាប់ផ្ទាល់: មុនពេលដាំ គេត្រូវយកគ្រាប់ពូជទៅហាលថ្ងៃរយៈពេល៣០នាទីទៅ១ម៉ោង បន្ទាប់មកយកគ្រាប់ពូជទៅត្រាំទឹកជាមួយសូលុយស្យុង (Captan 50%)wp រយៈពេល ២៥-៣០ នាទី ឬគេអាចយក (Captan ២,៥-៣ ក្រាមលាយជាមួយគ្រាប់ពូជទម្ងន់ ១ គ.ក្រ ទើបយកទៅដាំ។ មុនដាំគេកាប់រណ្តៅនៅលើរងចន្លោះ ១ ម៉ែត្រជម្រៅរណ្តៅ ៧-៨ ស.ម បន្ទាប់មកទើបដាំមួយរណ្តៅ ២-៣ គ្រាប់ ហើយគ្របកំទេចកំទីចំបើងស្ងួតពីលើ ទើបស្រោចទឹកតាមក្រោយមួយថ្ងៃពីរលើក។

### របៀបថែទាំកូនឪឡឹក

- ស្រោចទឹកកូនឪឡឹកឱ្យជោគនៅពេលព្រឹក និងពេលថ្ងៃ ។ មិនគួរស្រោចទឹកនៅពេលល្ងាចទេ វានឹងធ្វើឱ្យដីសើមពេលយប់ បណ្តាលឱ្យគ្រាប់សើមជ្រុល ឫសកូនឪឡឹកសើមពេក រួចហើយធ្វើឱ្យវាងាយរលួយ យ៉ាងឆាប់រហ័ស។

ខ . ការដាំដុះដោយកូនឪឡឹកបណ្តុះ

- កូនឪឡឹកមានអាយុ៧ថ្ងៃ (មានស្លឹក២ពេញលេញ) បន្ទាប់ពីដុះគ្រាប់ហើយយើងអាចយកកូននោះទៅដាំបាន។ បើយើងដាំកូនឪឡឹកដែលមានអាយុចាស់ជាងនេះ យើងនិងខាតផលប្រយោជន៍ដូចជា៖

  - កូនឪឡឹកខ្សោយ(តូចៗ)
  - ដើមឪឡឹកដុះលូតលាស់យឺត
  - កាត់បន្ថយទិន្នផល

- ត្រូវពង្រឹងកូនឪឡឹកមុនពេលដកយកទៅដាំ (បន្ទាប់ពីកូនឪឡឹកដុះបាន២ទៅ៣ថ្ងៃត្រូវបើកដំបូលរោងឱ្យត្រូវពន្លឺថ្ងៃ ដោយជៀសវាងពេលថ្ងៃត្រង់) និងបន្ថយការស្រោចទឹករហូតដល់ពេលយកកូនទៅដាំ។



ការពង្រឹងកូនឪឡឹកត្រឹមត្រូវនឹងទទួលបានអត្ថប្រយោជន៍ដូចជា៖

- ដើមកូនឪឡឹករឹងមាំល្អ
- កូនឪឡឹក មិនចាញ់អាកាសធាតុខាងក្រៅ
- មានការដាច់ឫសតិចតួចបំផុតនៅពេលដក កូនយកទៅដាំ
- កូនឪឡឹកមិនសន្លប់(អន់)ឬមានតិចតួចបំផុតបន្ទាប់ពីដាំហើយ
- ស្រោចទឹកកូនចំនួន២-៣ម៉ោងមុនដកយកដាំទើបដីមិនបែក និងដាំវានៅពេលរសៀល
- ស្រោច និងបញ្ចូលទឹកឱ្យជោគរងដាំនៅពេលព្រឹក។ បើយើងបានស្រោចទឹកឱ្យបានសព្វដីនៅពេលព្រឹកបែបនេះ គឺដីក្នុងរងមានភាពសើមបានយូរ ជួយកាត់បន្ថយការភាយកំដៅពីរងដែលគ្របប្លាស្ទីក រីឯកូនឪឡឹក ងាប់មានចំនួនតិចតួចបំផុតបន្ទាប់ពីដាំហើយ ជាពិសេសយើងងាយស្រួល



ដើរទៅតាមចន្លោះរងក្នុងពេលដាំ។



### ❁ របៀបដកកូនឪឡឹកចេញពីថាសបណ្ដុះ

* យកម្រាមដៃច្របាច់បាតថាសឬរុញដីក្នុងរន្ធនៅបាតថាសទៅលើ
* ដៃម្ខាងទៀតទាញគល់កូនឪឡឹកឡើង

### ❁ របៀបដាំកូនឪឡឹក

* ដាំកូនឪឡឹកត្រឹមដីកំណើត ទើបកូនដុះលូតលាស់បានល្អ
* កប់វាក្នុងរណ្ដៅជ្រៅលិចបាត់ដីកំណើតនោះកូនឪឡឹកលូតលាស់យឺត ឬងាប់បន្ទាប់ពីដាំហើយ។





## ៦. ការថែទាំ

### ៦.១ ការប្រើប្រាស់ជី

ការជ្រើសរើសប្រភេទជីសម្រាប់ដាក់ឪឡឹក ឱ្យត្រូវតាមពេលវេលាក្នុង

ដំណាក់កាលលូតលាស់នីមួយៗ បានត្រឹមត្រូវជាមួយបរិមាណដែលដំណាំត្រូវការនោះ យើងពិតជាចំណាយថវិកាទិញជីអស់តិច ហើយឪឡឹកនឹងផ្តល់ទិន្នផលបានខ្ពស់។

### ក. ប្រភេទជីនិងពេលវេលាប្រើប្រាស់ជី

ពូជឪឡឹកបង្កាត់ (អ៊ីប្រីដ) ត្រូវដាក់ជីបំប៉នឱ្យបានទៀងទាត់ ទើបវាអាចផ្តល់ផ្លែ ផ្កាបានច្រើន។ ជាការប្រសើរគួរដាក់ជីបំប៉នរៀងរាល់៧ទៅ១៥ថ្ងៃម្តងបន្ទាប់ពីដាំកូនឪឡឹកហើយ ប៉ុន្តែវាអាស្រ័យទៅតាមរដូវកាលដាំដុះប្រភេទដីនិងស្ថានភាពលូតលាស់ឪឡឹកផងដែរ។ ឧទាហរណ៍ប្រភេទដីខ្សាច់ត្រូវដាក់ជីឱ្យបានញឹកញាប់ តែដាក់បរិមាណតិចដោយសារប្រភេទដីនេះងាយហូរច្រោះជីទឹកលឿន ដូច្នេះបើយើងដាក់ជីច្រើននោះ វានឹងបាត់បង់ដោយសារហូរតាមទឹកក្នុងល្បឿនលឿនហើយដំណាំស្រូបយកបានតិចតួច ។

ជៀសវាងជ្រើសរើសជីដែលខូចគុណភាព (មានកកជាដុំៗឬសើម)និងដាក់ជីនៅពេលថ្ងៃក្តៅទៅលើដំណាំឪឡឹក កត្តាទាំងនេះនិងបង្កឱ្យឪឡឹកងាប់បាន។

**បរិមាណនិងពេលដាក់ជីលើដំណាំឪឡឹកលើផ្ទៃដី៥០០ម៉ែត្រការ៉េ**

| ចំនួនថ្ងៃបន្ទាប់ពីដាំ | ប្រភេទជី | ចំនួនជី/ដើម | ចំនួនដើម | ជីសរុប (គ.ក្រ) | ទីតាំងកប់ជីចម្ងាយពីគល់ |
|---|---|---|---|---|---|
| ទ្រាប់បាត | ជី ២០-២០-១៥ | ១៥ក្រាម (១ស្លាបព្រាបាយ) | ២២០ | ៣,៣ | ពង្រាយជី & ច្របល់ |
| ១០ ថ្ងៃ | ជី ២០-២០-១៥ | ១០ក្រាម (១ស្លាបព្រាបាយ) | ២២០ | ២,២ | ១០ ស.ម |
| | ជី៤៦-០-០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ២០ ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ១០ស.ម |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |

| | | | | | |
|---|---|---|---|---|---|
| ៣០ ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥ស.ម |
| | ជី ០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ៤០ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥ស.ម |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |
| ៥០ថ្ងៃ | ជី ២០-២០-១៥ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | ២៥ស.ម |
| | ជី០-០-៦០ | ៥ក្រាម (កន្លះស្លាបព្រាបាយ) | ២២០ | ១,១ | |

## ប្រការជៀសវាងនៅពេលដាក់ជី



គ្រប់ប្រភេទ ជីគីមីគ្រាប់ទាំងអស់ ៖

- មិនត្រូវយកជីដាក់នៅក្បែរគល់ឱឡឹកទដើទាំងនោះនិងបង្កឱ្យឆួលក្តៅធ្វើឱ្យវាងាប់បានយ៉ាងលឿន
- មិនត្រូវយកជីដាក់នៅលើដីចោលទេការដាក់ជីបែបនេះមានការខាតថវិកាជាច្រើនព្រោះថាដំណាំពុំអាចស្រូបជីនោះបានដោយសារជីទាំងនោះបានបាត់បង់ដោយសារកំដៅថ្ងៃនិងខ្យល់ដោយសារការហួតខ្លាំង។

### ខ.របៀបដាក់ជីក្នុងរងគ្របប្លាស្ទិកគ្របដីនិងចំបើង




- យើងត្រូវយកឈើមកបុកជារណ្តៅ ពីលើរងគ្របចំបើង ប្លាស្ទិក ជម្រៅប្រមាណជា ៥ សង់ទីម៉ែត្រ(កន្លះតឹក) នៅសងខាង រណ្តៅឪឡឹក សម្រាប់ដាក់ជី
- ជម្រៅរណ្តៅដាក់ជីត្រូវតែរាក់ល្មម ទើបឫសដំណាំអាចស្រូបយកជីនោះបាន។

## ៦.២ ការស្រោចទឹក

ដំណាំនេះត្រូវការទឹកជាមធ្យមចាប់ពីពេលដុះរហូតដល់វាចេញផ្កាឈ្មោល តែក្រោយពីដាំឪឡឹកមានក្តិប វាត្រូវការទឹកកាន់តែខ្លាំងរហូតពេលផ្លែចាប់ផ្តើមដាក់ជាតិស្ករ។

- គេអាចស្រោចរៀងរាល់ឆ្នាំ ត្រូវស្រោចទឹកនៅពេលព្រឹក ដោយបញ្ចូលទឹកតាមចន្លោះរង។ បើស្រោចទឹកពេលថ្ងៃត្រង់ ឬ ពេលល្ងាច (ដីសើមនៅពេលយប់) អាចធ្វើឱ្យឪឡឹកមានបញ្ហាដូចជា រលួយ ឬ រលាកដើម។
- ត្រូវស្រោចទឹកឱ្យបានទៀងទាត់ មិនត្រូវឱ្យដីស្ងួតជាពិសេសបន្ទាប់ពីដាំកូនហើយ ពីព្រោះកូនឪឡឹក ត្រូវការទឹក ជីសម្រាប់ដុះលូតលាស់ ឫស ដើម ស្លឹក ផ្កា ផ្លែ។
- បើពិនិត្យឃើញដីនៅក្បែគល់ឪឡឹកស្ងួត(មិនអាចលុញជាដុំមូលបាន) ត្រូវស្រោចទឹកបន្ថែម។ បើដីនៅក្បែរគល់ឪឡឹកសើមខ្លាំង (ច្របាច់ដីមានទឹកហៀរតាមម្រាមដៃ)មិនត្រូវដាក់ទឹកបន្ថែមទេ។ទឹកដក់ច្រើនពេកវាអាចបង្កឱ្យរលួយ

ឫសឬងាប់ដើម។





ចង្អូរវងសម្រាប់បញ្ចូលទឹក

## ៦.៣ ការជំរះស្មៅចង្រៃ

ត្រូវជំរះស្មៅក្នុងចម្ការឱ្យបានស្អាត ទោះបីជារងគ្របចំបើង ឬ ប្លាស្ទិក ក៏ដោយ ។ ស្មៅនៅតាមចន្លោះរងត្រូវដកចេញ ពីព្រោះវាជាជម្រកសត្វល្អិតចង្រៃបំផ្លាញឪឡឹក ហើយក៏ជាភ្នាក់ងារចម្លងជំងឺដល់ឪឡឹកផងដែរ។





## ៦.៤ ការកាត់តែងខ្នែង

ការកាត់ខ្នែងឪឡឹក ត្រូវធ្វើនៅពេលវាមានស្លឹក (ថ្នាំង) ទី៥ ។ នៅពេលនោះ យើងត្រូវកាត់ត្រួយនៅស្លឹកទី ៦ ហើយវានឹងបែកចេញខ្នែងពីស្លឹកថ្នាំងដែល

បានកាត់នោះ។ ក្នុងចំណោមត្រួយខ្នែងដែលបែក យើងអាចទុកតែត្រួយចំនួន ២ទៅ៣(យកត្រួយណាដែលលូតលាស់ថ្លោសល្អ)បើសិនជាមានផ្កានៅចន្លោះស្លឹកចេញពីដើមមេទៅ ចំនួន ១២ ស្លឹក (ថ្នាំងដើមខ្នែង) ត្រូវបេះផ្កាញី ចោលទាំងអស់។ រក្សាផ្កា និង ក្តិបនៅចន្លោះពីស្លឹក/ថ្នាំង ទី១៣ ឡើងទៅប៉ុណ្ណោះ។ ក្នុងខ្នែងនីមួយៗ ទុកតែក្តិបមួយណាដែលថ្លោសជាងគេ ឱ្យទៅជាផ្លែធំ។



ដើមមេកាត់(ក្រៀវ) ត្រួយ នៅស្លឹក(ថ្នាំង) ទី ៥





## ៧. ជំងឺ និងសត្វល្អិតចង្រៃ

## ៧. ១. ជំងឺដំណាំឪឡឹក

### ក. ជំងឺដៅនីមីដ្ឋូ (Downy Mildew)

ជំងឺនេះ ច្រើនចាប់ផ្តើមរាតត្បាតពីស្លឹកឪឡឹកចាស់ៗ មុន។ យើងអាចសង្កេតមើលឃើញ នៅលើស្លឹកនោះមានចំនុចរាងជ្រុងពណ៌លឿងខ្ចី និងវិវត្ត

ទៅរកពណ៌បៃតងប្រលែតពីចំនុចជ្រុងតូចៗទៅធំ។ នៅដំណាក់កាលជំងឺរាត ត្បាតខ្លាំងចំណុចរាងជ្រុងប្រែពណ៌ត្នោត ហើយស្លឹកស្ងួត។



ជំងឺនេះកើតឡើងនៅពេលណាមានអ័ព្ទ ធ្លាក់សន្សើមច្រើន មានភ្លៀង ធ្លាក់ញឹកញាប់ បង្កឱ្យស្លឹកឪឡឹកសើមរយៈពេល៥ទៅ៦ម៉ោងក្នុងអំឡុងពេល ដែលមានសីតុណ្ហភាពចុះមកត្រឹម២៥ទៅ៣០អងស្សាសេនោះវាជាពេលវេលា ដ៏ល្អសម្រាប់ជំងឺនេះដុះលូតលាស់បានយ៉ាងឆាប់រហ័ស។

ជំងឺនេះធ្វើឱ្យដើមឪឡឹកលូតលាស់មិនល្អ ដើមក្រិន ទិន្នផលថយចុះ។

**វិធីការពារជំងឺដោនីមីដូ ( Downy Mildew )**

- ជ្រើសរើសពូជដាំធន់នឹងជំងឺនេះ
- ត្រូវដាំពីគុម្ពមួយទៅគុម្ពមួយឱ្យរង្វើលព្រោះវាជួយឱ្យមានពន្លឺ និង ខ្យល់ចេញចូលគ្រប់គ្រាន់ធ្វើឱ្យស្លឹករហ័សស្ងួត
- មិនគួរស្រោចទឹកពីលើស្លឹក
- ជៀសវាងស្រោចទឹកពេលល្ងាច( សើមជ្រុល/ជោគជាំពេក )

❋ សំអាតដំណាំជម្រករបស់ជំងឺនេះចេញពីចម្ការ

❋ សំអាតកាកសំណល់បន្លែផ្សេងៗ បន្ទាប់ពីប្រមូលផលហើយ

❋ មិនគួរដាំឪឡឹកនៅជិតចម្ការបន្លែដែលមានកើតជំងឺប្រភេទនេះទេ

❋ បាញ់ថ្នាំកំចាត់ផ្សិតរវាងពី៥ទៅ១០ថ្ងៃម្តង ដូចជាថ្នាំមេតាឡាក់ស៊ីល (Metalaxyl) ថ្នាំប្រូក្លរ៉េស (Prochloraz) ឬថ្នាំហ្វូស៊ីលអាល់ (Fosetyl-Al)។ ថ្នាំនេះត្រូវបាញ់ឆ្លាស់គ្នាលាយជាមួយទឹកស្អិត ហើយបាញ់ពីក្រោមនិងលើផ្ទៃស្លឹកនៅពេលល្ងាច។







### វិធីកំចាត់ជំងឺដោនីមីជ្ជូ (Downy Mildew)

❋ កាត់ស្លឹកដែលមានជំងឺដាក់ថង់យកទៅកប់ចោល។ ការកាត់ស្លឹកមានជំងឺទម្លាក់ចោលក្នុងចម្ការ ស្ព័រជំងឺនេះនិងបាចសាចឆ្លងទៅដំណាំកាន់តែខ្លាំងជាងមុន។

❋ ជ្រើសរើសប្រភេទថ្នាំណាមួយបាញ់ឆ្លាស់គ្នា ពីខាងលើនិងក្រោមស្លឹក ដូចជាថ្នាំក្លរ៉ូថាឡូនីល (Chlorothalonil) ថ្នាំម៉ង់កូសែប(Mancozeb) ថ្នាំប្រូប៉ាម៉ូកាប (Propamocarb) ឬថ្នាំទ្រីហ្វ្លរហ្សីស្រ្តូប៊ីន (Trifloxystrobin)។ ថ្នាំនេះ

បាញ់មានប្រសិទ្ធភាពគួរលាយជាមួយទឹកស្អិត ហើយបាញ់នៅពេលល្ងាច។







### ខ. ជំងឺរួញស្លឹក( Watermelon Mosaic )៖

- ធ្វើឱ្យស្លឹកដំណាំឪឡឹកប្រែពណ៌បៃតង ទៅបៃតងចាស់ ហើយក្រាស់ បន្ទាប់មករួញស្លឹក ក្ដោបចុះក្រោម នៅវគ្គចេញផ្កា ផ្លែប្រែទៅជាក្រិន ជាដើម។
- វាបង្កឡើងដោយសត្វល្អិតម្យ៉ាងឈ្មោះថា Aphid





## ការការពារ ជំងឺរួញស្លឹក( Watermelon Mosaic )៖

ត្រូវប្រើពូជធន់ ធ្វើអនាម័យចម្ការ និងការពារកុំឱ្យមានពពួកសត្វល្អិតប្រភេទនេះ កើតមានច្រើននៅក្នុងចម្ការឪឡឹក។

## គ. ជំងឺរលួយឫស( Fusaium wilt )

* វាបង្កដោយមេរោគ Fusaium Oxy Sporum. f. Sp.neveums គេសង្កេតឃើញកើតជាញឹកញាប់នៅក្នុងរដូវក្តៅហើយសើម ។ នៅក្នុងវគ្គបន្តពូជ វាធ្វើឱ្យកូនដំណាំពុក រលួយគល់ដំណាំ និងស្រពោនលែងលូតលាស់បន្ត។





## ការការពារជំងឺរលួយឫស

* ប្រើថ្នាំពពួក Benomyl និងថ្នាំ Carbendazim
* ឬអាចប្រើថ្នាំពីរប្រភេទទៀត ដែលមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងជំងឺបង្កឡើយដោយពពួកផ្សិតគឺថ្នាំ Prochloraz និង Bromuconazole។



## ៧.២ សត្វល្អិតចង្រៃ

ក. ទ្រីប(Trips)

ត្រូវពិនិត្យ វែកឆែករកមើល សត្វទ្រីបឱ្យបានញឹកញាប់ ជាពិសេសនៅផ្នែកត្រួយឪឡឹក។ ទ្រីប គឺជាមូលហេតុធ្វើឱ្យត្រួយដំណាំឈប់លូតលាស់។

**វិធីការពារ**

- គួរដាំដោយប្រើគម្របប្លាស្ទីក
- ត្រូវបាញ់ទឹកស្រោចឱ្យចំត្រួយដំណាំ (បើមានលទ្ធភាព១ថ្ងៃ ២ម្តង)

**វិធីកំចាត់**

- បន្ថយការប្រើប្រាស់ជី អ៊ុយរ៉េ (៤៦-0-0)







⁕ ប្រើថ្នាំពុលកសិកម្មឆ្លាស់គ្នាណាមួយលាយជាមួយទឹកស្អិតដូចជាថ្នាំ អាបាមិចទីន (Abamectin) ឌីណូតីហ្វុយរង់ (Dinotefuran) អ៊ីមីដាក្លប្រីត (Imidacloprid) ថ្យាមេតូហ្សាម (Thiamethoxam) ឬថ្នាំឡាំដាស៊ីឡូស្រីន (Lambdacyhalothrin)។







ខ. ចៃ (Aprids)

ត្រូវពិនិត្យរកមើលចៃ ឱ្យបានញឹកញាប់ នៅផ្នែកខាងក្រោមស្លឹក ។ ចៃជាភ្នាក់ងារចម្លងជំងឺវីរុស ដែលបណ្តាលឱ្យស្លឹក និងត្រួយឪឡឹក រួញ។





### វិធីការពារ

- ដាំឪឡឹកឱ្យយរង្វើល
- កំចាត់ស្មៅនិងដំណាំជម្រកទ្រីបចេញពីក្នុងចម្ការ
- ស្រោចថ្នាំការពារសត្វល្អិតនៅនឹងកូនឪឡឹក មុនពេលយកវាទៅដាំ
- កប់ចោលកាកសំណល់ឪឡឹកនៅសល់បន្ទាប់ពីប្រមូលផលហើយ

### វិធានការកំចាត់

- កាត់ស្លឹកដែលមានចៃយកទៅកប់ ដុតចោល ឬក៏ញេចចៃដោយដៃ
- ជ្រើសរើសថ្នាំកំចាត់សត្វល្អិតណាមួយ ប្រើឆ្លាស់គ្នាលាយនិងទឹកស្អិត ហើយបាញ់នៅពេលត្រជាក់ដូចជា៖

ថ្នាំអាបាមិចទីន ( Abamectin )
ថ្នាំឌីណូតឺហ្វូរ៉ង់ ( Dinotefuran )
ឬថ្នាំហ្វីប្រូនីល ( Fipronil )
ថ្នាំឡាំដាស៊ីហាឡូស្រ៊ីន ( Lamdacyhalothrin ) ។










## ៨. ការប្រមូលផល

- ឪឡឹកអាចប្រមូលផលបានបន្ទាប់ពីដាំបានរយៈពេលពី៥០ ទៅ ៦០ថ្ងៃ តែវាអាស្រ័យទៅតាមប្រភេទពូជ

* ត្រូវបេះផ្លែឪឡឹករក្សាទងឱ្យជាប់ផ្លែដើម្បីរក្សាគុណភាព
* ត្រូវប្រើកាំបិតសម្រាប់កាត់ទងឪឡឹក
* មិនត្រូវទាញកន្ត្រាក់ផ្លែ ផ្តាច់ចេញពីដើមឡើយ។

ក្រោយដាំរហូតដល់ប្រមូលផលឪឡឹកទទួលបានទិន្នផលជាមធ្យម១៥ ទៅ១៧ តោនក្នុង១ ហិកតា៕





## ឯកសារយោង៖


១. សៀវភៅណែនាំបច្ចេកទេសផលិតកម្មដំណាំបន្លែ, ២០១៤

២. សៀវភៅបច្ចេកទេសដាំបន្លែសម្រាប់មន្ត្រីផ្សព្វផ្សាយកសិកម្ម, ឆ្នាំ២០១១

៣. កូនសៀវភៅដំណាំឪឡឹកនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម, ឆ្នាំ២០០៣

៤. ដំណាំឪឡឹក ស្ថានីយ៍ពិសោធន៍ពូជបន្លែក្បាលកោះ, ឆ្នាំ១៩៩៩៕



**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១២ ៩២ ៦៨ ៩២

០១៥ ៥៩ ២០ ២៧

**ទូរសារលេខ** : ០២៣ ២១ ០៩ ៤៨

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

Department of Agricultural Extension

**គេហទំព័រ** : http://www.maff.gov.kh

